ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

លេខ : ....៥.៦១........ក.ក.ជ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមគ្រូបង្គោលថ្នាក់ជាតិ
## សម្រាប់ការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- អនុក្រឹត្យលេខ ៧៧ អនក្រ-បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ
- យោងតាមការចាំបាច់

## ស ម្រេ ច

ប្រការ ១._

បង្កើតក្រុមគ្រូបង្គោលថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានសមាសភាពមកពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គម-ស៊ីវិល និងវិស័យឯកជន ។

សមាសភាពជាក់ស្តែងនៃក្រុមគ្រូបង្គោលត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់អគ្គលេខាធិការ (ក.ក.ជ.) ដោយមានការឯកភាពពីក្រសួង-ស្ថាប័នសាមី ។

ប្រការ ២.-

ក្រុមគ្រូបង្គោលថ្នាក់ជាតិ មានតួនាទីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា លើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយមានភារកិច្ចចម្បងៗដូចខាងក្រោម ÷

- រៀបចំ និងធ្វើការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- រៀបចំ និងធ្វើបច្ចុប្បន្នកម្មកម្មវិធីបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍
- ចូលរួមចំណែកផ្សព្វផ្សាយ និងទាក់ទងជាមួយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដើម្បីជំរុញឱ្យមានការគាំទ្រ និងប្រើប្រាស់សេវាកម្ម បណ្តុះបណ្តាលរបស់ក្រុមគ្រូបង្គោល
- ធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលនៃការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅគ្រប់កម្រិត
- ស្រាវជ្រាវ និងចងក្រងចំណេះដឹង បទពិសោធន៍ និងបេរៀនល្អៗពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភដើម្បីចែករំលែក និងផ្ទេរទៅឱ្យសិក្ខាកាម
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភជូនប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

ប្រការ ៣.-

ក្រុមគ្រូបង្គោលថ្នាក់ជាតិ ត្រូវប្រជុំសាមញ្ញ ប្រាំមួយ(០៦)ខែម្តង និងប្រជុំវិសាមញ្ញតាមការចាំបាច់តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤.-

ការប្រព្រឹត្តទៅរបស់ក្រុមគ្រូបង្គោលថ្នាក់ជាតិ ត្រូវកំណត់ក្នុងគោលការណ៍ណែនាំសម្រាប់ក្រុមគ្រូបង្គោលថ្នាក់ជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភដែលនឹងត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំតាមការចាំបាច់ ។

ប្រការ ៥.-

ក្រុមគ្រូបង្គោលថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយជាសេនាធិការ ។ លេខាធិការដ្ឋាន មានមូលដ្ឋាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងមានភារកិច្ចចម្បងៗ ដូចខាងក្រោម ÷

- ទទួលបន្ទុកសម្របសម្រួលការងារទូទៅទាក់ទងនឹងការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ធ្វើការទាក់ទងឱ្យបានជិតស្និទ្ធ និងជាប្រចាំជាមួយសមាជិកក្រុមគ្រូបង្គោលដើម្បីផ្លាស់ប្តូរព័ត៌មាន

- ដើរតួនាទីយ៉ាងសំខាន់ក្នុងការទាក់ទងជាមួយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីជំរុញឱ្យមានការគាំទ្រ និងប្រើប្រាស់សេវាកម្មបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ពិភាក្សា និងចចារជាមួយស្ថាប័នដែលត្រូវការសេវាកម្មបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីឈានទៅរៀបចំកិច្ចព្រមព្រៀងសម្រាប់ចុះហត្ថលេខា
- ធ្វើការទាក់ទង និងសម្របសម្រួលជាមួយសមាជិកក្រុមគ្រូបង្គោលសម្រាប់វគ្គបណ្តុះបណ្តាលនីមួយៗ
- ទទួលបន្ទុកចាត់ចែង ទុកដាក់ និងថែទាំសម្ភារៈនិងបរិក្ខាបណ្តុះបណ្តាល
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភជូនប្រធានក្រុមគ្រូបង្គោល
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមគ្រូបង្គោលប្រគល់ជូន ។

លេខាធិការដ្ឋានមានលេខាធិការ មួយ(០១) រូប និងមានជំនួយការមួយចំនួនតាមការចាំបាច់ ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

អគ្គលេខាធិការ អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ ៥ ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី**

**អេដ្ឋ.យឹម ឆៃលី**

**ចម្លងជូន:**

- អនុប្រធាន ក.ក.ជ.
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី**
- ក្រសួង ស្ថាប័នសាមី នៃសមាជិកក្រុមគ្រូបង្គោល
- អគ្គលេខាធិការ និងអគ្គលេខាធិការរង ក.ក.ជ.
- គ្រប់សមាជិកក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- ដូចមានក្នុងប្រការ ១
- ឯកសារ-កាលប្បវត្តិ